# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

## សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## ការថ្កោលទោសចំពោះការប្រើប្រាស់អំពើហិង្សាធ្ងន់ធ្ងរចំពោះប្រជាពលរដ្ឋ

ភ្នំពេញ, ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤

បន្ទប់ស្ថានការណ៍នៃអង្គការ សមាគម សង្គមស៊ីវិលនៅកម្ពុជា សូមថ្កោលទោសចំពោះការប្រើអំពើហិង្សាធ្ងន់ធ្ងរ រហូតដល់មានការបាញ់ប្រហារប្រជាពលរដ្ឋ (ប្រុស/ស្រី)ដែលបណ្តាលឲ្យស្លាប់ និងរងរបួស ព្រមទាំងការចាប់ខ្លួនប្រជាពលរដ្ឋ និងការរំលោភបំពានចូលក្នុងលំនៅដ្ឋានប្រជាពលរដ្ឋ ពីសំណាក់កងកម្លាំងប្រដាប់អាវុធនៃរដ្ឋាភិបាល នៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងនៅតាមបណ្តោយផ្លូវវែងស្រែង រាជធានីភ្នំពេញ។ នេះជាករណីរំលោភសិទ្ធិមនុស្ស ដ៏ធ្ងន់ធ្ងរមួយដែលមិនអាចទទួលយកបាន។

បន្ទប់ស្ថានការណ៍នៃអង្គការ សមាគម សង្គមស៊ីវិលនៅកម្ពុជាស្នើឲ្យរាជរដ្ឋាភិបាលត្រូវបញ្ឈប់ការបាញ់ប្រហារ និងមធ្យោបាយហិង្សាផ្សេងៗពីសំណាក់ក្រុមកម្លាំងប្រដាប់អាវុធ លើប្រជាពលរដ្ឋស្លូតត្រង់ជាបន្ទាន់។ ព្រមជាមួយនេះ រាជរដ្ឋាភិបាលត្រូវស្វែងរកមធ្យោបាយដោយសន្តិវិធីដើម្បីឆ្លើយតបនឹងការទាមទារដំឡើងប្រាក់ខែរបស់កម្មករ។ យើង ក៏សំណូមពរផងដែរឲ្យមានការដោះលែងប្រជាពលរដ្ឋដែលត្រូវបានចាប់ខ្លួនទាក់ទិននឹងព្រឹត្តិការណ៍នេះមានដូចជា លោក វន ពៅ ប្រធាន សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) និងអ្នកផ្សេងទៀតជាដើម។

បន្ទប់ស្ថានការណ៍នៃអង្គការ សមាគមសង្គមស៊ីវិលនៅកម្ពុជា មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះស្ថានភាពបាតុកម្ម និងស្ថានភាពវិបត្តិនយោបាយ នៅក្នុងសង្គមនាពេលចុងក្រោយនេះ។ ដូចនេះយើង ស្នើសុំឲ្យសហគមន៍អន្តរជាតិ និងអ្នកសង្កេតការណ៍ជាតិ និង អន្តរជាតិ ចូលរួមឃ្លាំមើលព្រឹត្តិការណ៍ខាងលើនេះ និងអន្តរាគមឲ្យបានទាន់ពេលវេលាដើម្បីបញ្ឈប់ករណីរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរដូចករណីខាងលើ។


**<u>ព័ត៌មានបន្ថែមសូមទាក់ទង៖</u>**

| | | |
|---|---|---|
| ០១. លោក ធន សារាយ | ប្រធាននៃសមាគមអាដហុក&ខុមហ្វ្រែល | ០១៦ ៤៤ ០០ ៤៤ |
| ០២. លោកស្រី ធីតា ឃីះ | នាយិកាអង្គការសីលការ | ០១២ ៨៣ ៨៤ ៦៤ |
| ០៣. លោកស្រី រស់ សុភាព | នាយិកាអង្គការGADC | ០១២ ៦២ ៧៨ ៥៧ |
| ០៤. លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិច | ០១២ ៩៥ ៩៦ ៦៦ |

| | | |
|---|---|---|
| ០៥. លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | ០១២ ៨០ ១២ ៣៥ |
| ០៦. លោក យង់ គិមអេង | ប្រធាន PDP-Center | ០១៦ ៨២ ៨២ ១១ |
| ០៧. លោក ព្រាប កុល | នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា | ០១២ ៨៧ ៧៨ ៣៣ |
| ០៨. លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| ០៩. លោក សុខ ពិទូរ្យ | នាយកប្រតិបត្តិក្រុមប្រឹក្សាយុវជនកម្ពុជា | ០១៧ ២៧ ៣៣ ០៣ |
| ១០. លោក សាម អ៊ីន | នាយកប្រតិបត្តិនៃLWD | ០១២ ៥៥ ១៨ ៨៦ |
| ១១. គាន ពន្លក | នាយកប្រតិបត្តិរងនៃ DHRAC | ០១២ ៥៥ ១៤ ៦៦ |
| ១២.លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិ CCIM | ០៦០ ៤០ ៩៩ ៩៩ |
| ១៣. លោក ម៉ាក់ ចំរើន | ប្រធានសមាគមយុវជនខ្មែរ | ០១៧ ៧៨ ៨៩ ៥៥ |
| ១៤. លោក ម៉ម សម្បត្តិ | នាយកប្រតិបត្តិDPA | ០១២ ៧៧ ៩៧ ៣៤ |
| ១៥. លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការCOMFREL | ០១២ ៩៤ ២០ ១៧ |